# ការវាយតម្លៃបឋមលើផលប៉ះពាល់
# សេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន

បញ្ញត្តិកម្ម ៖ សេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន
ក្រសួង ៖ ឧស្សាហកម្ម និងសិប្បកម្ម
លេខយោង ៖
កាលបរិច្ឆេទចាប់ផ្តើម ៖ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧
កាលបរិច្ឆេទបញ្ចប់ ៖ ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨

### អត្ថាធិប្បាយសង្ខេបអំពីសំណើរបញ្ញត្តិកម្ម

### រៀបរាប់អំពីចំណុចសំខាន់ៗ ដូចជាកាតព្វកិច្ច វិសាលភាព និងគោលបំណង

ធម្មជាតិបង្កើតឱ្យមាននូវភាពចាំបាច់និងប្រទាក់ក្រឡា ដែលជួយទ្រទ្រង់គ្នាទៅវិញទៅមកដោយមិនអាចកាត់ផ្តាច់ចេញពីគ្នាបាន។ ដែលក្នុងនោះទឹកជាធាតុដ៏សំខាន់ចាំបាច់ និងមិនអាចខ្វះបានសម្រាប់ជីវិតក្នុងលោក។ ភពផែនដីត្រូវការទឹកសម្រាប់ក្សានូវតុល្យភាព ជីវិតទាំងឡាយត្រូវការភពផែនដីសម្រាប់រស់នៅ និងត្រូវការទឹកសម្រាប់ទ្រទ្រង់ផងដែរ។ អត្ថិភាពនៃជីវិតមនុស្ស សត្វ និងរុក្ខជាតិ គឺអាស្រ័យនឹងអត្ថិភាពនៃទឹក ការបាត់បង់ទឹកជីវិតក៏ត្រូវបាត់បង់ទៅតាមនោះដែរ។ ហើយទន្ទឹមនឹងនោះទឹកក៏អាចបំផ្លាញជីវិតក្នុងលោកផងដែរ។

កាលពីសម័យដើម មនុស្សមិនបានចាប់អារម្មណ៍អំពីសារៈប្រយោជន៍នៃទឹកឡើយ ដោយទឹកមាននៅពាសពេញលើភពផែនដី កាលណាត្រូវការទឹក ពួកគេអាចយកទឹកនៅតាមទន្លេ ព្រែក ស្ទឹង បឹងបួរ ទឹកភ្លៀងជាដើម ហើយមិនបានគិតដល់ផលប៉ះពាល់នានាដែលកើតចេញពីទឹកនោះទេ។ ក្រោយមក វិទ្យាសាស្ត្រមានការរីកចម្រើនទៅមុខជាលំដាប់ឥតឈប់ឈរ ធ្វើឱ្យបរិយាកាសសង្គមប្រែជាមានភាពអាប់អួរ និងបង្កភាពគ្រោះថ្នាក់ តាមរយៈការរីកសាយភាយជាតិវិទ្យុសកម្ម សារធាតុគីមីក្នុងស្រទាប់ផែនដី បរិយាកាស និងគ្រឿងឧបភោគបរិភោគដែលបណ្តាលឱ្យជីវិតក្នុងលោកជួបប្រទះនូវភាពស្មុគស្មាញ និងកាន់តែមានភាពទ្រុឌទ្រោមទៅៗរហូតដល់មានការបាត់បង់អត្ថិភាពមុនកាលកំណត់។ បុព្វហេតុទាំងនេះនាំឱ្យការប្រើប្រាស់ទឹកតាមបែបធម្មជាតិ( ទឹកឆៅ )ជួបបញ្ហាប្រឈមយ៉ាងខ្លាំង ជាពិសេសសម្រាប់យកមកបរិភោគ។

កន្លងមកប្រទេសកម្ពុជាធ្លាប់មានវិបត្តិជុំវិញបញ្ហាកង្វះទឹកប្រើប្រាស់ជារឿយៗ និងនាថ្ងៃទី១-២ ខែឧសភា ឆ្នាំ២០១៨ នៅភូមិស្រែននិងភូមិអាលច ឃុំកន្ទួត ស្រុកចិត្របុរី ខេត្តក្រចេះ ការយកទឹកចេញពីព្រែកទេនិងអូរគគី មកប្រើប្រាស់របស់ប្រជាពលរដ្ឋ បានជួយប្រទះនូវបញ្ហាពុល ដែលការពុលនេះបណ្តាលមកពីស្រាស និងទឹកព្រែកនិងអូរខាងលើ (បើតាមបណ្តាញសារព័ត៌មានហ្វ្រេសញ៉ូវ(Fresh News) និងសេចក្តីប្រកាសព័ត៌មានរវាងក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល និងក្រសួងសុខាភិបាល ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨) ហើយបណ្តាលឱ្យមាន មនុស្សស្លាប់ជាបន្តបន្ទាប់ចំនួន១៣នាក់ និងចូលសម្រាកនៅមន្ទីរពេទ្យប្រមាណជាង២០០នាក់ ជាហេតុនាំឱ្យរាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងក្រសួង-ស្ថាប័នពាក់ព័ន្ធ បានខិតខំដោះស្រាយជាបន្ទាន់ និងជាបន្តបន្ទាប់ រហូតទទួលបានលទ្ធផលជាវិជ្ជមាន។

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាស្ថាប័នដែលមានសមត្ថកិច្ចលើសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជន តាមរយៈនេះ ក្រសួងបានខិតខំយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងការផ្គត់ផ្គង់ទឹកស្អាត និងធ្វើយ៉ាងណាឱ្យការផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាតប្រព្រឹត្តទៅប្រកបដោយគុណភាព តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងនិរន្តរភាព ហើយក្រសួងតែងតែអនុវត្តការងារទៅតាមភាពចាំបាច់នៃតម្រូវការ ដោយបានចេញនូវលិខិតបទដ្ឋានក្រោមច្បាប់នានា ទោះបីជាពុំទាន់មានលិខិតបទដ្ឋានគតិយុត្តគោលដែលជាត្រីវិស័យសម្រាប់អនុវត្តតាមនៅឡើយក្តី។ ការអនុវត្តបែបនេះធ្វើឱ្យការផ្គត់ផ្គង់ទឹកស្អាតមិនមានលក្ខណៈជាប្រព័ន្ធ

ដោយកន្លែងខ្លះមានច្បាប់និងកន្លែងខ្លះគ្មានច្បាប់អនុញ្ញាត កន្លែងខ្លះមានទឹកស្អាតនិងកន្លែងខ្លះទៀតគ្មានទឹកស្អាតប្រើប្រាស់ កន្លែងខ្លះទឹកស្អាតមានភាពអនុលោមនិងខ្លះទៀតទឹកស្អាតមិនមានភាពអនុលោមតាមស្តង់ដាគុណភាពទឹកស្អាត ដែលជាហេតុបណ្តាលឱ្យប៉ះពាល់ដល់គោលនយោបាយទឹករបស់ជាតិ និងដល់សុខុមាលភាពរបស់អ្នកប្រើប្រាស់ទឹកស្អាត។ នេះសបញ្ជាក់នូវកង្វះកិច្ចសហការរវាងសមត្ថកិច្ចពាក់ព័ន្ធវិស័យសាធារណៈនឹងវិស័យឯកជន និងមិនបានចូលរួមដឹងសុខទុក្ខ និងដោះស្រាយបញ្ហាឱ្យចំគោលដៅ និងទាន់ពេលវេលា។ ម្យ៉ាងទៀតបញ្ហាប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្ម ការភ្ជាប់បណ្តាញ ប្រសិទ្ធភាព គុណភាព និងនិរន្តរភាពទឹក ជាបញ្ហាដែលត្រូវយកចិត្តទុកដាក់ខ្ពស់បំផុតពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងស្ថាប័នពាក់ព័ន្ធ ជាពិសេសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

លក្ខណៈពិសេសរបស់ទឹកស្អាត គឺមិនអាចមានការប្រកួតប្រជែងលើទីផ្សារដូចទំនិញនានាឡើយ ដោយតំបន់មួយមិនអាចមានអ្នកផ្គត់ផ្គង់ទឹកស្អាតពីរ ឬច្រើនត្រួតគ្នាទេ តែក៏មិនអាចមិនមានទឹកស្អាតសម្រាប់ផ្គត់ផ្គង់ជូនប្រជាពលរដ្ឋប្រើប្រាស់ជាប់ជាប្រចាំដែរ ហើយបញ្ហាថ្លៃទឹកក៏រឹតតែមិនអាចអនុញ្ញាតឱ្យផលិតករកំណត់តាមទំនើងចិត្ត និងមិនអាចឱ្យបញ្ចុះតម្លៃតាមការចង់បានរបស់អ្នកប្រើប្រាស់ទឹកស្អាតផងដែរ។

ជាទូទៅទឹកស្អាតស្ថិតក្នុងវិស័យសាធារណៈដែលជាបន្ទុករបស់រដ្ឋក្នុងការផ្គត់ផ្គង់ជូនប្រជាពលរដ្ឋ តែដោយបច្ចុប្បន្នលទ្ធភាពមានកំណត់នៅឡើយទាមទារឱ្យមានការចូលរួមពីវិស័យឯកជន ដើម្បីអភិវឌ្ឍវិស័យទឹកស្អាតឱ្យបានសមស្របតាមតម្រូវការនៃកំណើនប្រជាពលរដ្ឋ។

ការកសាងនីតិរដ្ឋ ការលើកស្ទួយកម្រិតជីវភាព និងសុខុមាលភាពប្រជាពលរដ្ឋ ជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះវិស័យទឹកស្អាតជាវិស័យអត្ថិភាពមួយដែលចាំបាច់ត្រូវធ្វើយ៉ាងណាឱ្យមានជំនឿចិត្តពីគ្រប់មជ្ឈដ្ឋាន ជាពិសេសពីអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ទឹកស្អាត។ ក្នុងការអភិវឌ្ឍន៍វិស័យទឹកស្អាតប្រកបដោយចីរភាព ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងនិរន្តរភាព ទាមទារឱ្យមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ជាពិសេសត្រូវមានការទទួលខុសត្រូវខ្ពស់ពីសមត្ថកិច្ចជំនាញផងដែរ។

ប្រភេទបញ្ញត្តិកម្ម៖

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| ☑ | ☐ | ☐ | ☐ | ☐ | ☐ | ☐ |

**ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ៖**

☑សេដ្ឋកិច្ច ☑ សង្គមកិច្ច ☐បរិស្ថាន ☐.... ផ្សេងៗ

I. ការកំណត់បញ្ហា

**-ក្រមខណ្ឌច្បាប់៖** មិនទាន់មានគោលការណ៍ និងក្របខណ្ឌគតិយុត្តគោលច្បាស់លាស់សម្រាប់ការធ្វើនិយ័តកម្មសេវាផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន ប្រកបដោយសនិទានភាព ប្រសិទ្ធភាព និងតម្លាភាពនៅឡើយ ដោយកន្លងមកការកំណត់នូវលក្ខខណ្ឌតម្រូវមូលដ្ឋាន និងនីតិវិធីសម្រាប់ផ្តល់ កែប្រែ ព្យួរ និងដកហូតអាជ្ញាបណ្ណអាជីវកម្ម កំណត់ត្រឹមប្រកាសរបស់ក្រសួងដែលជាប្រភេទលិខិតបទដ្ឋានគតិយុត្តមានឋានានុក្រមកម្រិតទាប ធ្វើឱ្យវិស័យឯកជនមិនសូវមានទំនុកចិត្ត និងមិនទាន់ឆ្លើយតបទៅនឹងការវិវត្តន៍របស់សង្គម ដើម្បីឱ្យស្របតាមប្រទេសនីតិរដ្ឋដែលតម្រូវឱ្យមានលិខិតបទដ្ឋានគតិយុត្តគោលមួយច្បាស់លាស់។

**-វិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាត៖** វិស័យទឹកស្អាតនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជានៅមានកម្រិតនៅឡើយដោយនៅតំបន់ខ្លះមិនទាន់មានសេវាកម្មផ្គត់ផ្គង់ទឹកស្អាត និងតំបន់ខ្លះទៀតមានសេវាផ្គត់ផ្គង់ទឹកស្អាត។ តំបន់មានសេវា

កម្មផ្គត់ផ្គង់ទឹកស្អាតមួយចំនួនមិនបានពង្រីកវិសាលភាពតាមដែនសេវារបស់ខ្លួនដែលទទួលបានការអនុញ្ញាតពីក្រសួង។ តំបន់សេវាកម្មខ្លះទឹកស្អាតមានភាពអនុលោម និងខ្លះទៀតមិនមានភាពអនុលោមតាមស្តង់ដាគុណភាពទឹកស្អាត ជាពិសេសក្នុងតំបន់សេវាកម្មផ្គត់ផ្គង់ទឹកស្អាតដែលគ្រប់គ្រងដោយឯកជន។

**-បញ្ហាប្រភពទឹក៖** ជាបញ្ហាចំបងដែលត្រូវដោះស្រាយសម្រាប់សេវាករ ដើម្បីធានាបាននូវនិរន្តភាព និងគុណភាព។ បច្ចុប្បន្នបញ្ហាប្រភពទឹកមានលក្ខណៈខុសគ្នារវាងតំបន់មួយទៅតំបន់មួយ ដោយតំបន់ខ្លះមានប្រភពទឹកគ្រប់គ្រាន់ និងតំបន់ខ្លះទៀតមិនមានប្រភពទឹកគ្រប់គ្រាន់ ហើយពិបាកក្នុងការស្វែងរកប្រភពទឹក ជាពិសេសនៅពេលជួបវិបត្តិគ្រោះរាំងស្ងួតម្តងៗ។ គុណភាពប្រភពទឹក ជាបញ្ហាចំបងដែលត្រូវដោះស្រាយ ដែលប្រភពទឹកទាំងនេះត្រូវមានកិច្ចការពារយ៉ាងម៉ឺងម៉ាត់ និងប្រភពទឹកខ្លះទៀតបានមកពីការប្រើប្រាស់ម្តងរួចមកហើយ ជួនកាលមានសំរាម ការចិញ្ចឹមសត្វ ការបង្ហូរកាកសំណល់ ការបន្ទោរបង់ដាក់ ឬក៏មានសារជាតុគីមីក្នុងនោះ ដូចជា ជាតិអាសេនិក ជាដើម។

**-បញ្ហាប្រព្រឹត្តិកម្ម៖** ជាបញ្ហាគោលដែលត្រូវមានការយកចិត្តទុកដាក់ខ្ពស់ ចាប់តាំងពីដំណាក់កាលដំបូងរហូតដល់បញ្ចប់នៃការធ្វើប្រព្រឹត្តិកម្មទឹកស្អាត។ ការកសាងអាងប្រព្រឹត្តិកម្ម ត្រូវធ្វើតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវ និងតាមស្ថានភាពប្រភពទឹក។ ការបញ្ចូលសារជាតុគីមីដើម្បីចាប់កករ និងសម្លាប់មេរោគ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវស្របតាមលក្ខណៈបច្ចេកទេស។

**-បញ្ហាភ្ជាប់បណ្តាញ៖** ជាបញ្ហាចោទមួយ ដែលទាមទារឱ្យសមត្ថកិច្ចពាក់ព័ន្ធមានការយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់ ព្រមទាំងមានកិច្ចសហការគ្នាល្អ ដែលកន្លងមកសមត្ថកិច្ចជំនាញនីមួយៗបំពេញភារកិច្ចដោយមិនបានគិតគូពីផលប៉ះពាល់នានាជុំវិញការអនុវត្តភារកិច្ចរបស់ខ្លួន នេះសបញ្ជាក់ពីកង្វះកិច្ចសហការរវាងសមត្ថកិច្ចពាក់ព័ន្ធ ដែលជាហេតុនាំឱ្យសេវាករផ្គត់ផ្គង់ទឹកស្អាតមានការរំខាន និងខាតបង់(ពេលវេលានិងធនធាន) ជាពិសេសធ្វើឱ្យអ្នកផ្គត់ផ្គង់ ក៏ដូចជាអ្នកប្រើប្រាស់ទឹកស្អាតបាត់បង់នូវទំនុកចិត្តមកលើសមត្ថកិច្ច។ ជួនកាលការមិនសហការនេះអាចបណ្តាលឱ្យមានការលេចធ្លាយ ឬដាច់បណ្តាញចែកចាយទឹកស្អាត ហើយថែមទាំងមិនមានការទទួលខុសត្រូវផងដែរ។ ការជីកថ្នល់ដើម្បីតភ្ជាប់បណ្តាញមិនត្រូវបានអនុញ្ញាត ឬមានការអនុញ្ញាតដែរតែតម្រូវឱ្យមានការបង់ថ្លៃខ្ពស់ និងតម្រូវឱ្យមានការជួសជុលថ្នល់ឡើងវិញផងដែរ។

**-បញ្ហាថ្លៃទឹក៖** កំពុងមានភាពចម្រូងចម្រាសរវាងអ្នកផ្គត់ផ្គង់នឹងអ្នកប្រើប្រាស់ទឹកស្អាត ដោយប្រជាពលរដ្ឋទាមទារឱ្យលក់ទឹកស្អាតក្នុងតម្លៃថោក រីឯអ្នកផ្គត់ផ្គង់ទាមទារឱ្យមានតម្លៃខ្ពស់។

### I.១ បញ្ហាពាក់ព័ន្ធផ្សេងៗទៀតដែលបញ្ញត្តិកម្មនេះអាចជួយដោះស្រាយបានផងដែរ

**-លើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ៖** ទឹកស្អាតជាទឹកដែលមានភាពអនុលោមតាមស្តង់ដាគុណភាពទឹកស្អាត ហើយរក្សាបាននូវស្ថេរភាព គុណភាព និងនិរន្តរភាពទឹក ដែលជាទំនុកចិត្តរបស់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋ ក្នុងការយកទៅប្រើប្រាស់ និងបរិភោគ។

**-កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋ៖** ការប្រើប្រាស់ទឹកស្អាតមានលក្ខណៈងាយស្រួលមាននិរន្តរភាព២៤/២៤ម៉ោង អាចប្រើប្រាស់ចេញពីក្បាលរ៉ូប៊ីណេដោយផ្ទាល់ និងភ្លាមៗតាមតម្រូវការ ដែលជាហេតុនាំឱ្យប្រជាពលរដ្ឋមានឱកាសយកពេលវេលាទៅប្រកបអាជីវកម្ម និងមុខរបរផ្សេងៗ។ ម្យ៉ាងទៀតកាត់បន្ថយនូវការចំណាយក្នុងការយកទឹកមកប្រើប្រាស់ និងបង្កើននូវសុខុមាលភាពជូនប្រជាពលរដ្ឋផងដែរ។

**-និរន្តរភាពទឹកស្អាត៖** តាមរយៈកិច្ចអន្តរាគមន៍របស់រដ្ឋ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីស្វែងរកប្រភពទឹកដែលមានលក្ខណៈគ្រប់គ្រាន់ និងមានសក្តានុពលជានិរន្ត ដើម្បីយកទៅប្រព្រឹត្តិកម្មជាទឹកស្អាតសម្រាប់ផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ជាប្រចាំ។ ប្រភពទឹក ចាំបាច់ត្រូវមានកិច្ចការពារ និងត្រួតពិនិត្យឱ្យបានត្រឹមត្រូវ និងមានការទទួលខុសត្រូវខ្ពស់ ជាពិសេសពីសំណាក់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**-បង្កើនទំនុកចិត្ត និងទាក់ទាញការវិនិយោគមកប្រទេសកម្ពុជា៖** ច្បាប់ជាប្រភេទលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមខ្ពស់និងកម្រិតជាតិ មានលក្ខណៈទូទៅនិងមិនចំពោះ ព្រមទាំងមានភាពប្រាកដនិយម ដែលជាហេតុនាំឱ្យមានទំនុកចិត្តពីសំណាក់អ្នកវិនិយោគជាតិ និងអន្តរជាតិ និងជាមូលដ្ឋានក្នុងការសម្រេចដាក់ទុនវិនិយោគលើវិស័យទឹកស្អាត នៅព្រះរាជាណាចក្រកម្ពុជា ។

**-សុខដុមរមនីយកម្ម រវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ទឹកស្អាត៖** អាចទទួលយកបានតាមរយៈភាពអនុលោមតាមស្តង់ដាគុណភាពទឹកស្អាត និងថ្លៃទឹកសមរម្យ ដែលមានសុខដុមរូបនីយកម្ម រវាងអ្នកផ្គត់ផ្គង់ អ្នកប្រើប្រាស់ទឹកស្អាត និងស្ថាប័នមានសមត្ថកិច្ច ក៏ដូចជារាជរដ្ឋាភិបាល។

**I.២ សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តមានស្រាប់ដែលពាក់ព័ន្ធ ឬប្រហាក់ប្រហែល។ ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនទាន់គ្រប់គ្រាន់?**

**-ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹក៖** ច្បាប់នេះមានគោលដៅជំរុញឱ្យមានការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាពនៅក្នុងព្រះរាជាណាក្រកម្ពុជា ដើម្បីសម្រេចបាននូវការងារអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ច្បាប់នេះបានកំណត់អំពី៖ សិទ្ធិនិងកាតព្វកិច្ចនៃអ្នកប្រើប្រាស់ទឹកផងដែរ គោលការណ៍គ្រឹះសំខាន់ៗសម្រាប់ការគ្រប់គ្រងធនធានទឹក និងការចូលរួមរបស់សហគមន៍អ្នកប្រើប្រាស់ទឹកក្នុងការអភិវឌ្ឍន៍ធនធានទឹកប្រកដោយនិរន្តរភាព។

**-ច្បាប់ស្តីពីការរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ៖** ច្បាប់នេះមានគោលដៅជំរុញឱ្យមាការរៀបចំទីក្រុង និងតំបន់ជនបទនៃព្រះរាជាណាចក្រកម្ពុជា ដោយគោរពនូវផលប្រយោជន៍រួម និងបុគ្គល ធានានូវតម្លៃសម្បត្តិធម្មជាតិ សម្បត្តិវប្បធម៌ និងធានាបាននូវការអភិវឌ្ឍន៍សេដ្ឋកិច្ច វិស័យទេសចរណ៍ និងរក្សាបាននូវគុណភាពបរិស្ថាន។ តាមរយៈនោះ ប្លង់ប្រើប្រាស់ដីធ្លី និងសំណង់ត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់អំពីតំបន់ដែលត្រូវបានប្រើប្រាស់។

**-ច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ៖** ច្បាប់នេះចែងអំពីការគ្រប់គ្រងសហគ្រាសសាធារណៈ និងលក្ខខណ្ឌដែលត្រូវអនុវត្តចំពោះលក្ខន្តិកៈគតិយុត្ត ការប្រព្រឹត្តទៅ និងការត្រួតពិនិត្យ។ សហគ្រាសសាធារណៈជាសហគ្រាសដែលមានដើមទុនទាំងអស់ឬភាគច្រើនជារបស់រដ្ឋ មានបេសសកម្មបង្កលក្ខណៈដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ជាអាទិ៍ក្នុងការបង្កើនតម្លៃធនធានធម្មជាតិ និងការបង្កើតអាជីព។

**-ប្រកាសស្តីពីនីតិវិធីសម្រាប់ការផ្តល់ កែប្រែ ព្យួរ និងដកហូតអាជ្ញាបណ្ណអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត៖** ចែងអំពីនីតិវិធី និងលក្ខខណ្ឌតម្រូវក្នុងការផ្តល់ កែសម្រួល បន្ត ព្យួរ និងដកហូត ប្រកាសអនុញ្ញតអាជីវកម្ម និងចែងពីសិទ្ធិ និងកាតព្វកិច្ចរបស់អ្នកទទួលបានច្បាប់អនុញ្ញាតអាជីវកម្មទឹកស្អាត និងអ្នកប្រើប្រាស់ទឹកស្អាត។ បញ្ញត្តិខាងលើនេះ ជាបញ្ញត្តិដែលមានឋានានុក្រមទាបត្រឹមកម្រិតក្រសួង ដែលងាយនឹងកែប្រែ ហើយធ្វើឱ្យអ្នកវិនិយោគ ក៏ដូចជាអ្នកប្រើប្រាស់ពុំសូវមានទំនុកចិត្ត។

**-ប្រកាសស្តីពីនីតិវិធីនៃការកំណត់ថ្លៃលក់ទឹកដែលអ្នកផ្គត់ផ្គង់សេវាទឹកស្អាតមានសិទ្ធិយកពីអ្នកទទួលសេវាទឹកស្អាត៖** ចែងអំពីរូបមន្តក្នុងការកំណត់ថ្លៃលក់ទឹកស្អាត ដើម្បីសុខដុមរូបនីយកម្មរវាងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ទឹកស្អាត។

**-ប្រកាស ស្តីពីស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិ៖** ប្រកាសនេះមានគោលដៅកំណត់អំពី បែបបទ និងនីតិវិធីដើម្បីធានាភាពអនុលោមតាមស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិ ដើម្បីឱ្យគ្រប់ប្រព្រឹត្តិកម្មទឹកស្អាតអនុលោមតាម។

លិខិតបទដ្ឋានគតិយុត្តដូចបានរៀបរាប់ខាងលើនេះ មិនទាន់បំពេញបាននូវតម្រូវការដាក់ស្តែងសម្រាប់គ្រប់គ្រងវិស័យទឹកស្អាតក្នុងព្រះរាជាណាចក្រកម្ពុជានៅឡើយទេ ព្រោះច្បាប់ដូចបានរៀបរាប់ខាងលើមិនមែនជាច្បាប់សម្រាប់គ្រប់គ្រងទឹកស្អាតឡើយ ហើយប្រកាសដូចបានរៀបរាប់ខាងលើជាប្រកាសពាក់ព័ន្ធនឹងវិស័យទឹកស្អាតប៉ុន្តែមានឋានានុក្រមទាបជាងច្បាប់ មានលក្ខណៈមិនប្រាកដនិយម និងមិនមានទំនុកចិត្តពីសំណាក់អ្នកវិនិយោគ ក៏ដូចជាអ្នកប្រើប្រាស់ទឹកស្អាតផងដែរ។

## I.៣ ផលប៉ះពាល់

ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន មិនត្រឹមតែមិនមានផលប៉ះពាល់ជាវិជ្ជមានទេ សំណើនេះបានបង្កើតនូវភាពគ្រប់ជ្រុងជ្រោយ ប្រាកដនិយម ទំនុកចិត្ត និងមានការទាក់ទាញការវិនិយោគមកប្រទេសកម្ពុជា ដើម្បីរួមចំណែកជួយបង្កើននូវកម្រិតជីវភាពប្រជាពលរដ្ឋ តាមរយៈសេវាកម្មផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាព និរន្តរភាព ប្រសិទ្ធភាព ថ្លៃសមរម្យ និងចូលរួមដោះស្រាយបានរាល់ភាពអសកម្មនានាដែលកើតមានជាយថាហេតុ។

## I.៤ តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?

ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនមិនមានផលប៉ះពាល់ជាវិជ្ជមានដល់ការប្រកួតប្រជែងទេ ដោយច្បាប់នេះចែងនូវដែនសមត្ថកិច្ចច្បាស់លាស់ ក្នុងការកំណត់តំបន់សេវាកម្មសម្រាប់សេវាករនីមួយៗ ហើយសេវាករនីមួយៗមានដែនសេវាកម្មផ្សេងៗគ្នា (ដោយមិនមានតំបន់សេវាកម្មជាន់គ្នាទេ)។ ជាទូទៅ សេវាកម្មផ្គត់ផ្គង់ទឹកស្អាតត្រូវបានអនុវត្តដោយរដ្ឋ ដោយឡែកសម្រាប់បច្ចុប្បន្នភាពនៃតម្រូវការកម្ពុជា សេវាកម្មផ្គត់ផ្គង់ទឹកស្អាតត្រូវបានអនុវត្តដោយរដ្ឋ និងឯកជន។

## II. គោលបំណង

គោលបំណងនៃច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជននេះ មានដូចខាងក្រោម៖

-ប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេសមានទឹកស្អាតប្រើប្រាស់ដូចៗគ្នា

-ទឹកស្អាតទូទាំងប្រទេសមានភាពអនុលោមតាមស្តង់ដាទឹកស្អាតនៃព្រះរាជាណាចក្រកម្ពុជា

-និរន្តរភាពទឹកស្អាតគឺ២៤ម៉ោងលើ២៤ម៉ោង

-ថ្លៃទឹកមានលក្ខណៈសមរម្យអាចទទួលយកបានទាំងអស់គ្នា ទាំងអ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់ទឹកស្អាត

-ផ្តល់នូវទំនុកចិត្ត ទាំងសេវាករ និងអ្នកប្រើប្រាស់ទឹកស្អាតលើភាពច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ចំគោលដៅ ប្រកបដោយគុណតម្លៃ គណនេយ្យភាព និងប្រសិទ្ធផល។

## III. ជម្រើស

ដើម្បីដោះស្រាយបញ្ហាដូចមានលើកឡើងខាងលើ ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តក្រសួងឧស្សាហកម្មនិងសិប្បកម្ម បានលើកយកជម្រើសចំនួន ០២ (ពីរ) មកធ្វើការសិក្សាវិភាគ ដូចខាងក្រោម៖

**-ជម្រើសទី១ ៖ រក្សាស្ថានភាពដើម**

រក្សាស្ថានភាពដើម គឺតម្រូវឱ្យសេវាកម្មទឹកស្អាតត្រូវបន្តអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដូចជា៖

-ប្រកាស ស្តីពីនីតិវិធីសម្រាប់ការផ្តល់ កែប្រែ ព្យួរ និងដកហូតអាជ្ញាបណ្ណអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត

-ប្រកាស ស្តីពីនីតិវិធីនៃការកំណត់ថ្លៃលក់ទឹកដែលអ្នកផ្គត់ផ្គង់សេវាទឹកស្អាតមានសិទ្ធិយកពីអ្នកទទួលសេវាទឹកស្អាត

-ប្រកាស ស្ដីពីស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិ ។ល។

ដោយមានការចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសទាំងលើប្រភពទឹករហូតដល់ភ្ជាប់បណ្ដាញជូនអ្នកប្រើប្រាស់ ការពិនិត្យគុណភាព ការស្វែងរកជំនួយបច្ចេកទេសនិងឥណទាន ការកំណត់ថ្លៃទឹក ជាដើម។

**-ជម្រើសទី២ ៖ សំណើបញ្ញត្តិកម្ម**

សំណើសេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន គឺជាលិខិតបទដ្ឋានគតិយុត្តមានឋានានុក្រមខ្ពស់កម្រិតជាតិ ដែលកើតចេញពីឆន្ទៈទូទៅរបស់ប្រជាពលរដ្ឋតាមរយៈសិទ្ធិតំណាង មានភាពប្រាកដនិយម ច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយ ដែលជាទីជឿជាក់ពីសំណាក់ប្រជាពលរដ្ឋ សេវាករ និងអ្នកវិនិយោគ។

សមត្ថកិច្ចជំនាញត្រូវបានកំណត់នូវសិទ្ធិ និងការទទួលខុសត្រូវច្បាស់លាស់ ដើម្បីធានាបាននូវគុណភាពនៃសេវាសាធារណៈជូនដល់ធុរជន និងអ្នកប្រើប្រាស់។

## V. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយកាតព្វកិច្ច និងផលចំណេញ

### V.១ ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម | I.**ភារកិច្ច**<br>១.ផ្តល់ប្រកាសអនុញ្ញាត<br>ក.ប្រកាសសុពលភាព ៣ឆ្នាំចុងក្រោយ<br>-សម្រាប់អ្នកដែលមានប្រកាសចាស់ដែលចេញពីអតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងមិនមានលទ្ធភាពក្នុងការសុំប្រកាសអនុញ្ញាត ដែលមានសុពលភាព២០ឆ្នាំ។<br>-លក់ពាក្យ និងទទួលពាក្យដោយតម្រូវឱ្យធុរជនភ្ជាប់មកជាមួយនូវប្រកាសចាស់។<br><br>-ផ្តល់ប្រកាសអនុញ្ញាតមានសុពលភាព៣ឆ្នាំចុងក្រោយ។<br><br>ខ.ប្រកាសជំនួស(សុពលភាព២០ឆ្នាំ)<br>-សម្រាប់បុគ្គលដែលមានប្រកាសអនុញ្ញាតចាស់ហើយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានប្រកាសអនុញ្ញាតដែលមានសុពលភាព២០ឆ្នាំ។ | I.**ភារកិច្ច**<br>១.ដាក់ពាក្យស្នើសុំប្រកាស<br>ក.ប្រកាសសុពលភាព ៣ឆ្នាំចុងក្រោយ<br>-សម្រាប់អ្នកដែលមានប្រកាសចាស់ដែលចេញពីអតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងមិនមានលទ្ធភាពក្នុងការសុំប្រកាសអនុញ្ញាត ដែលមានសុពលភាព២០ឆ្នាំ។<br>-ទិញពាក្យ និងដាក់ពាក្យមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដោយភ្ជាប់មកជាមួយនូវប្រកាសចាស់។<br>-ទទួលប្រកាសអនុញ្ញាតមានសុពលភាព៣ឆ្នាំចុងក្រោយពីក្រសួង។<br><br>ខ.ប្រកាសជំនួស(សុពលភាព២០ឆ្នាំ)<br>-សម្រាប់បុគ្គលដែលមានប្រកាសអនុញ្ញាតចាស់ហើយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានប្រកាសអនុញ្ញាតដែលមានសុពលភាព២០ឆ្នាំ។<br>-ត្រូវដាក់ពាក្យស្នើសុំប្រកាសជំនួស ដោយភ្ជាប់នូវផែនការអាជីវកម្មរយៈពេល៥ឆ្នាំ និងផែនទី |

| | | |
|---|---|---|
| | -ទទួលពាក្យស្នើសុំប្រកាសជំនួស ដោយអ្នកស្នើសុំមានការឯកភាពលើថ្លៃទឹកដែលក្រសួងបានកំណត់ ព្រមទាំងតម្រូវឱ្យភ្ជាប់នូវផែនការអាជីវកម្មរយៈពេល៥ឆ្នាំ និងផែនទីតំបន់សេវាកម្ម។<br>ក្នុងករណីអ្នកស្នើសុំមានប្រកាសអនុញ្ញាតចាស់ និងមិនមានការឯកភាពលើថ្លៃទឹកដែលកំណត់ដោយក្រសួង អ្នកស្នើសុំត្រូវដាក់ពាក្យសុំដោយមានភ្ជាប់មកជាមួយនូវសមិទ្ធិលទ្ធភាព របាយការណ៍ប្រតិបត្តិការអាជីវកម្ម៣ឆ្នាំចុងក្រោយ និងឯកសារពាក់ព័ន្ធ។<br><br>-ផ្តល់ប្រកាសអនុញ្ញាតជំនួស។<br><br>**គ.ប្រកាសអនុញ្ញាតផ្ទាល់(សុពលភាព២០ឆ្នាំ)**<br>-ក្រសួងអនុញ្ញាតជាគោលការណ៍លើការសិក្សាសមិទ្ធិលទ្ធភាព(សិក្សារយៈពេល៦ខែ ហើយអាចពន្យាពេល៣ខែ ដោយដាក់ពាក្យមុនយ៉ាងតិច២សប្តាហ៍ មុនផុតសុពុលភាពនៃការសិក្សាដំបូង)។<br><br>-តម្រូវឱ្យអ្នកដាក់ពាក្យស្នើសុំ ភ្ជាប់ជាមួយនូវឯកសារសមិទ្ធិលទ្ធភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (៣ច្បាប់) និងលិខិតបញ្ជាក់ចំនួនស្ថិតិប្រជាជន ដែលមានការបញ្ជាក់ពីសាលាឃុំ។<br><br>-ពិនិត្យ និងវាយតម្លៃលើពាក្យស្នើសុំ ដោយគណៈកម្មាធិការ ផ្សព្វផ្សាយនិងទទួលយោបល់ពីសាធារណៈជនលើសេចក្តីព្រាងប្រកាសក្នុងរយៈពេល២០ថ្ងៃ គិតចាប់ពីថ្ងៃផ្សព្វផ្សាយ(ប្រសិនជាមានការតវ៉ា ដោះស្រាយតាមរយៈវេទិការសាធារណៈ)។<br><br>-ផ្តល់ប្រកាសអនុញ្ញាតផ្ទាល់ដល់អ្នកស្នើសុំ។ | តំបន់សេវាកម្ម ប្រសិនបើមានការឯកភាពតាមថ្លៃទឹកដែលក្រសួងបានកំណត់។<br>ប្រសិនបើមិនមានការឯកភាពលើថ្លៃទឹកដែលក្រសួងបានកំណត់ ត្រូវដាក់ពាក្យសុំដោយភ្ជាប់មកជាមួយនូវសមិទ្ធិលទ្ធភាព របាយការណ៍ប្រតិបត្តិការអាជីវកម្ម៣ឆ្នាំចុងក្រោយ និងឯកសារពាក់ព័ន្ធ។<br><br>-ទទួលប្រកាសអនុញ្ញាតជំនួសពីក្រសួង។<br><br>**គ.ប្រកាសអនុញ្ញាតផ្ទាល់(សុពលភាព២០ឆ្នាំ)**<br>-សុំគោលការណ៍សិក្សាសមិទ្ធិលទ្ធភាពពីក្រសួង(សិក្សារយៈពេល៦ខែ ហើយអាចពន្យាពេល៣ខែ ដោយដាក់ពាក្យមុនយ៉ាងតិច២សប្តាហ៍ មុនផុតសុពុលភាពនៃការសិក្សាដំបូង)។<br><br>-ត្រូវដាក់ពាក្យស្នើសុំ ដោយភ្ជាប់ជាមួយនូវឯកសារសមិទ្ធិលទ្ធភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ (៣ច្បាប់) និងលិខិតបញ្ជាក់ចំនួនស្ថិតិប្រជាជន ដែលមានការបញ្ជាក់ពីសាលាឃុំ។<br><br>-ទទួលប្រកាសអនុញ្ញាតផ្ទាល់ពីក្រសួង។ |

| | | |
|---|---|---|
| | **ឃ.ប្រកាសប្រកួតប្រជែង** | **ឃ.ប្រកាសប្រកួតប្រជែង** |
| | -ពិនិត្យ និងឯកភាពលើការសិក្សាសមិទ្ធិលទ្ធភាព និងការអង្កេតទីតាំងភូមិសាស្ត្រ( ចំនួនប្រជាជន ប្រភពទឹក ទីតាំងសាងសង់ ស្ថានីយ៍បូមទឹក និងស្ថានីយ៍សំអាតទឹក) ដែលរៀបចំដោយអង្គការក្រៅរដ្ឋាភិបាល ឬក្រសួង។<br>-ជូនដំណឹងស្តីពីការចូលរួមដេញថ្លៃ (រយៈពេលដាក់ពាក្យចូលរួមដេញថ្លៃមានចំនួន៤៥ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹង )។ | |
| | -លក់ និងទទួលពាក្យចូលរួមដេញថ្លៃក្នុងតំបន់សេវាកម្ម កាលបរិច្ឆេទឈប់ទទួលពាក្យ គឺ២ម៉ោងមុនពេលផុតកំណត់ ៤៥ថ្ងៃនេះ។ | -ទិញពាក្យ និងដាក់ពាក្យចូលរួមដេញថ្លៃក្នុងតំបន់សេវាកម្ម ក្នុងអំឡុងពេលដែលក្រសួងចេញសេចក្តីជូនដំណឹងដែលមានរយៈពេល៤៥ថ្ងៃ នៃថ្ងៃធ្វើការ (ការឈប់ទទួលពាក្យគឺ២ម៉ោងមុនពេលផុតកំណត់ ៤៥ថ្ងៃនេះ)។ |
| | -រៀបចំកិច្ចប្រជុំបឋមដើម្បីណែនាំអំពីការរៀបចំឯកសារចូលរួមដេញថ្លៃ( ចន្លោះរយៈពេលពី ១០ - ១៤ ថ្ងៃ នៃកាលបរិច្ឆេទលក់ និងទទួលពាក្យដេញថ្លៃ)។ | -ចូលរួមក្នុងអង្គប្រជុំដើម្បីទទួលព័ត៌មានពាក់ព័ន្ធនឹងការរៀបចំឯកសារដេញថ្លៃ។ |
| | -ទទួលពាក្យពីអ្នកស្នើសុំចូលរួមដេញថ្លៃដោយមានការតម្រូវះ<br>➢ ឱ្យមានទុនវិនិយោគយ៉ាងតិច ៣៥% នៃទុនវិនិយោគសរុប<br>➢ តម្កល់ប្រាក់កក់ធានាចូលរួមដេញថ្លៃនៅធនាគារចំនួន៥០០០ ដុល្លាអាមេរិក ដោយមានលិខិតបញ្ជាក់ត្រឹមត្រូវ។ | -អ្នកដាក់ពាក្យស្នើសុំចូលរួមដេញថ្លៃត្រូវះ<br>➢ មានទុនវិនិយោគយ៉ាងតិច ៣៥% នៃទុនវិនិយោគសរុប<br>➢ តម្កល់ប្រាក់កក់ធានាចូលរួមដេញថ្លៃនៅធនាគារចំនួន៥០០០ ដុល្លាអាមេរិក ដោយមានលិខិតបញ្ជាក់ត្រឹមត្រូវ។ |
| | -សហការជាមួយដៃគូអភិវឌ្ឍន៍រៀបចំការដេញថ្លៃ ដែលសមាសភាពចូលរួមដេញថ្លៃ មាន តំណាងក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដៃគូអភិវឌ្ឍន៍ អាជ្ញាធរមូលដ្ឋាន អ្នកចូលរួមដេញថ្លៃ និងសាធារណៈជន នៅទីតាំងសមស្របណាមួយ។ | -នាពេលដេញថ្លៃ អ្នកដេញថ្លៃមានសិទ្ធិតវ៉ាចំពោះភាពមិនប្រក្រតីនៃការដេញថ្លៃ ។ |

| | | |
|---|---|---|
| | -បន្ទាប់ពីមានការដេញថ្លៃជាសាធារណៈ រួចមក គណៈកម្មការដេញថ្លៃ ធ្វើការវាយតម្លៃលើសំណុំ ឯកសារ ហើយត្រូវផ្តល់ព័ត៌មានអំពីជ័យលាភីដល់អ្នក ដែលបានដាក់ពាក្យស្នើសុំ។ | |
| | -តម្រូវឱ្យអ្នកដែលដេញថ្លៃបាន ធ្វើលិខិតផ្លូវការឯក ភាពទទួលយកគម្រោងក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពី ក្រសួងបានប្រកាសលទ្ធផលនៃការដេញថ្លៃជាផ្លូវការ ដោយមានភ្ជាប់មកជាមួយ៖<br>➢ ផែនការសាងសង់បណ្តាញរយៈពេល៥ឆ្នាំ<br>➢ ប្លង់តំបន់សេវាកម្ម។ | -អ្នកដែលដេញថ្លៃបាន ត្រូវធ្វើលិខិតផ្លូវការឯក ភាពទទួលយកគម្រោងក្នុងរយៈពេល១០ថ្ងៃ បន្ទាប់ពីក្រសួងបានប្រកាសលទ្ធផលនៃការដេញ ថ្លៃជាផ្លូវការ ដោយមានភ្ជាប់មកជាមួយ៖<br>➢ ផែនការសាងសង់បណ្តាញរយៈពេល៥ឆ្នាំ<br>➢ ប្លង់តំបន់សេវាកម្ម។ |
| | -ផ្តល់ប្រកាសអនុញ្ញាតប្រកួតប្រជែង។ | -ទទួលប្រកាសអនុញ្ញាតប្រកួតប្រជែង។ |
| | **ង.ប្រកាសអនុញ្ញាតអចិន្ត្រៃយ៍(សហគ្រាស សាធារណៈ)**<br>-សម្រាប់រដ្ឋាករទឹកស្វយ័ត និងរដ្ឋាករទឹក សាធារណៈ (សហគ្រាសទាំងនេះបង្កើតឡើងដោយ អនុក្រឹត្យ និងប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅ របស់មន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ដែលជាប្រកាសរៀបចំអង្គការ-ស្ថាប័ន រួចហើយ)។<br><br>-ប្រធានរដ្ឋាករទឹកស្វយ័ត និងរដ្ឋាករទឹកសាធារណៈ ខេត្តតាមរយៈប្រធានមន្ទីរសាមី ត្រូវធ្វើពាក្យសុំប្រកាស អនុញ្ញាតអចិន្ត្រៃយ៍មកក្រសួង ដើម្បីទទួលបាន ប្រកាសអនុញ្ញាត។ | **ង.ប្រកាសអនុញ្ញាតអចិន្ត្រៃយ៍(សហគ្រាស សាធារណៈ)** |
| | **២.វិញ្ញាបនបត្រប្រតិបត្តិការ(សុពលភាព៥ឆ្នាំ)**<br>**ក.សម្រាប់វិញ្ញាបនបត្រប្រតិបត្តិការដំបូង៖** | **២.វិញ្ញាបនបត្រប្រតិបត្តិការ(សុពលភាព៥ឆ្នាំ)**<br>**ក.សម្រាប់វិញ្ញាបនបត្រប្រតិបត្តិការដំបូង៖**<br>-បន្ទាប់ពីបញ្ចប់ការសាងសង់ប្រព័ន្ធផលិតកម្ម និងបណ្តាញចែកចាយរួច ប្រតិបត្តិករត្រូវដាក់ ពាក្យស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការមកក្រសួង (ដែលក្នុងប្រកាសស្តីពីនីតិវិធីសម្រាប់ការចេញ កែសម្រួល បន្ត ព្យួរ និងដកហូត ប្រកាសអនុញ្ញាត |

| | | |
|---|---|---|
| | -បន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការពីប្រតិបត្តិករទឹកស្អាតឯកជន ក្រុមការងារអធិការកិច្ចនៃនាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង ត្រូវចុះពិនិត្យភាពត្រឹមត្រូវនៃការសាងសង់មធ្យោបាយផលិតកម្ម និងប្រព័ន្ធចែកចាយទឹកស្អាតទៅតាមបទដ្ឋានគតិយុត្ត និងលក្ខណៈបច្ចេកទេសដែលបានកំណត់ដោយក្រសួង ហើយទឹកស្អាតដែលនឹងចែកចាយមានគុណភាព និងសុវត្ថិភាពត្រឹមត្រូវតាមស្តង់ដាគុណភាពទឹកផឹកជាតិ ដល់មូលដ្ឋានដែលបានស្នើសុំធ្វើអាជីវកម្ម។<br><br>-បន្ទាប់ពីពិនិត្យរួចមក ក្នុងករណី៖<br>➢ មានភាពអនុលោម ក្រសួងត្រូវចេញវិញ្ញាបនបត្រប្រតិបត្តិការ ជូនដល់ប្រតិបត្តិករ<br>➢ មិនមានភាពអនុលោម ក្រសួងតម្រូវឱ្យប្រតិបត្តិករធ្វើការកែតម្រូវនូវចំណុចខ្វះខាតឡើងវិញ។<br><br>**ខ.សម្រាប់វិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់៖** | ឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត តម្រូវឱ្យប្រតិបត្តិករដាក់ពាក្យស្នើសុំមកក្រសួង ដើម្បីសុំឱ្យក្រសួងចុះធ្វើអធិការកិច្ចបញ្ជាក់ពីភាពត្រឹមត្រូវនៃការសាងសង់មធ្យោបាយផលិតកម្ម និងប្រព័ន្ធចែកចាយទឹកស្អាត ទៅតាមបទដ្ឋានគតិយុត្ត និងលក្ខណៈបច្ចេកទេស ដែលបានកំណត់ដោយក្រសួង ហើយទឹកស្អាតដែលនឹងចែកចាយមានគុណភាព និងសុវត្ថិភាពត្រឹមត្រូវតាមស្តង់ដាគុណភាពទឹកផឹកជាតិ។<br><br>-ប្រតិបត្តិករ អាច៖<br>➢ ទទួលបានវិញ្ញាបនបត្រប្រតិបត្តិការ ក្នុងករណីមានភាពអនុលោម<br>➢ ធ្វើការកែតម្រូវនូវចំណុចខ្វះខាតឡើងវិញ ក្នុងករណីមិនមានភាពអនុលោម។<br><br>**ខ.សម្រាប់វិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់៖**<br><br>-ក្នុងរយៈពេលយ៉ាងយូរ ៩០ (កៅសិប) ថ្ងៃ មុនពេលផុតសុពលភាពវិញ្ញាបនបត្រប្រតិបត្តិការ |

| | | |
|---|---|---|
| | | ប្រតិបត្តិករ ត្រូវដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់មកក្រសួង ដើម្បីសុំឱ្យក្រសួងចុះធ្វើអធិការកិច្ចបញ្ជាក់ពីនិរន្តរភាពនៃមធ្យោបាយផលិតកម្ម និងប្រព័ន្ធចែកចាយទឹកស្អាត ទៅតាមបទដ្ឋានគតិយុត្ត និងលក្ខណៈបច្ចេកទេស ដែលបានកំណត់ដោយក្រសួង ហើយទឹកស្អាតដែលបាននិងកំពុងចែកចាយមានគុណភាព និងសុវត្ថិភាពត្រឹមត្រូវតាមស្តង់ដាគុណភាពទឹកផឹកជាតិ។ |
| | -ក្នុងរយៈពេល២០ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលសំណុំឯកសារស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់ពីប្រតិបត្តិករទឹកស្អាតឯកជន ក្រសួងត្រូវចាត់បញ្ជូនក្រុមការងារអធិការកិច្ចនៃនាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង ចុះបញ្ជាក់ពីនិរន្តរភាពនៃមធ្យោបាយផលិតកម្ម និងប្រព័ន្ធចែកចាយទឹកស្អាត ទៅតាមបទដ្ឋានគតិយុត្ត និងលក្ខណៈបច្ចេកទេស ដែលបានកំណត់ដោយក្រសួង ហើយទឹកស្អាតដែលបាននិងកំពុងចែកចាយមានគុណភាព និងសុវត្ថិភាពត្រឹមត្រូវតាមស្តង់ដាគុណភាពទឹកផឹកជាតិ ដល់មូលដ្ឋានដែលបានស្នើសុំធ្វើអាជីវកម្ម។<br>ក្នុងករណីមិនបានចុះធ្វើអធិការកិច្ចក្នុងរយៈពេល ២០ថ្ងៃ នៃថ្ងៃធ្វើការខាងលើ ក្រសួងត្រូវផ្តល់ព័ត៌មាន និងត្រូវកំណត់ពេលវេលាចុះធ្វើអធិការកិច្ចច្បាស់លាស់ដល់អ្នកស្នើសុំ។ ក្នុងករណី ខកខានមិនបានជូនដំណឹងដូចបានកំណត់ខាងលើ ចាត់ទុកថាក្រសួងបានយល់ព្រមចេញវិញ្ញាបនបត្រប្រតិបត្តិការជូនអ្នកស្នើសុំហើយ។ | |
| | -បន្ទាប់ពីពិនិត្យរួចមក ក្នុងករណីៈ<br>➢ មានភាពអនុលោម ក្រសួងត្រូវចេញវិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់ ជូនដល់ប្រតិបត្តិករ | -ប្រតិបត្តិករ អាចៈ<br>➢ ទទួលបានវិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់ ក្នុងករណីមានភាពអនុលោម |

| | | |
|---|---|---|
| | ➢ មិនមានភាពអនុលោម ក្រសួងត្រូវធ្វើការណែនាំជាលាយលក្ខអក្សរដល់អ្នកស្នើសុំនូវចំណុចខ្វះខាតដែលត្រូវកែលម្អ និងត្រូវស្នើសុំឱ្យមានការធ្វើអធិការកិច្ចឡើងវិញ។ | ➢ ធ្វើការកែតម្រូវនូវចំណុចខ្វះខាតដែលបានលើកឡើងដោយក្រសួង រួចស្នើសុំឱ្យមានការធ្វើអធិការកិច្ចឡើងវិញ ក្នុងករណីមិនមានភាពអនុលោម។ |
| | **៣.គុណភាពទឹក**<br>-បញ្ជ្រាបការយល់ដឹង និងភ្ញាក់រលឹកយកសំណាកទឹកមកធ្វើការវិភាគឱ្យបានទៀងទាត់។ | **៣.គុណភាពទឹក** |
| | -ធ្វើការវិភាគគុណភាពទឹក៖<br>➢ ត្រូវទទួលវិភាគគុណភាពទឹករៀងរាល់៣ខែម្តង<br>➢ ក្នុងករណីចាំបាច់ មន្ត្រីមានសមត្ថកិច្ចត្រូវចុះត្រួតពិនិត្យ និងធ្វើការវិភាគគុណភាពទឹក ដល់ទីតាំងអាជីវកម្ម តាមសភាពជាក់ស្តែង ។ | -ធ្វើការវិភាគគុណភាពទឹក៖<br>➢ យកសំណាកទឹករៀងរាល់៣ខែម្តង មកធ្វើការវិភាគគុណភាពនៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា<br>➢ ក្នុងករណីចាំបាច់ សហការជាមួយមន្ត្រីមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យ និងធ្វើការវិភាគគុណភាពទឹក។ |
| | -ចុះពិនិត្យតាមដានដោយជូនដំណឹង ឬមិនមានការជូនដំណឹងជាមុន និងចុះពេលដែលមានបាតុភាពជាក់ស្តែង។ | -សហការជាមួយមន្ត្រីមានសមត្ថកិច្ចក្នុងការចុះពិនិត្យតាមដានក្នុងទីតាំងអាជីវកម្ម និងបណ្តាញចែកចាយ។ |
| | -ជួយសម្របសម្រួល និង/ឬ បណ្តុះបណ្តាលបច្ចេកទេសដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។ | -ចូលរួមក្នុងវគ្គបណ្តុះបណ្តាលលើបច្ចេកទេសផ្គត់ផ្គង់ទឹកស្អាត។ |
| | -ពង្រឹងយន្តការគ្រប់គ្រង និងតាមដានត្រួតពិនិត្យប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្មទឹក និងប្រព័ន្ធចែកចាយ។ | -អនុវត្តយន្តការគ្រប់គ្រង និងតាមដានត្រួតពិនិត្យប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្មទឹក និងប្រព័ន្ធចែកចាយ។ |
| | **៤.ថ្លៃទឹក**<br>-ថ្លៃទឹកត្រូវបានកំណត់រៀងរាល់៥ឆ្នាំម្តងដោយ៖<br>➢ លើកទី១៖នៅពេលស្នើសុំប្រកាសអនុញ្ញាតធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត។ ការកំណត់ថ្លៃ | **៤.ថ្លៃទឹក**<br>-ដាក់សំណុំឯកសារស្នើសុំប្រកាសអនុញ្ញាតធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ដែលក្នុងនោះមានការវិភាគថ្លៃដើម និងកំណត់ថ្លៃលក់ទឹកស្អាតបឋម |

| | | |
|---|---|---|
| | ទឹកដោយផ្អែកលើការវិភាគថ្លៃដើមដែលភ្ជាប់ជាមួយនូវសំណុំឯកសារស្នើសុំប្រកាសអនុញ្ញាតធ្វើអាជីវកម្ម។<br>➢ លើកទី២និងលើកបន្ទាប់៖ ការកំណត់ថ្លៃទឹកលើកទី២ និងលើកបន្ទាប់មកទៀតនេះគឺផ្អែកលើរបាយការណ៍អាជីវកម្មប្រចាំឆ្នាំទាំង៥ឆ្នាំ(របាយការណ៍ប្រចាំឆ្នាំពីឆ្នាំទី១រហូតដល់ឆ្នាំទី៥) ។ ក្នុងករណីមិនមានរបាយការណ៍ប្រចាំឆ្នាំទាំង៥ឆ្នាំទេ ត្រូវមានរបាយការណ៍៣ឆ្នាំចុងក្រោយ។<br><br>-ធ្វើការកំណត់ថ្លៃលក់ទឹក ដោយមានការចូលរួមពិគ្រោះយោបល់ពីប្រតិបត្តិករផ្គត់ផ្គង់ទឹក។<br><br>II.**ការចំណាយ**<br>១.ផ្តល់ប្រកាសអនុញ្ញាត<br>ក.ប្រកាសសុពលភាព ៣ឆ្នាំចុងក្រោយ<br>ចំណាយក្នុងការបោះពុម្ពសំណុំលិខិតស្នើសុំ។<br><br>ខ.ប្រកាសជំនួស(សុពលភាព២០ឆ្នាំ)<br>ចំណាយក្នុងការបោះពុម្ពសំណុំលិខិតស្នើសុំ។ | -ចូលរួមពិគ្រោះយោបល់កំណត់ថ្លៃទឹកតាមការអញ្ជើញរបស់ក្រសួងដោយមានភ្ជាប់របាយការណ៍អាជីវកម្មប្រចាំឆ្នាំទាំង៥ឆ្នាំ ឯកសារពាក់ព័ន្ធ និងអ្នកបច្ចេកទេស។<br><br>II.**ការចំណាយ**<br>១.ដាក់ពាក្យស្នើសុំប្រកាស<br>ក.ប្រកាសសុពលភាព ៣ឆ្នាំចុងក្រោយ<br>ចំណាយសម្រាប់ប្រកាសអនុញ្ញាត។<br><br>ខ.ប្រកាសជំនួស(សុពលភាព២០ឆ្នាំ)<br>-ចំណាយសម្រាប់ប្រកាសអនុញ្ញាត។<br>-ចំណាយលើការរៀបផែនការអាជីវកម្មរយៈពេល៥ឆ្នាំ និងផែនទីតំបន់សេវាកម្ម ប្រសិនបើមានការឯកភាពតាមថ្លៃទឹកដែលក្រសួងបានកំណត់។<br>-ចំណាយលើការសិក្សាសមិទ្ធិលទ្ធភាព ប្រសិនបើមិនមានការឯកភាពលើថ្លៃទឹកដែលក្រសួងបានកំណត់។ |

| | | |
|---|---|---|
| | គ.ប្រកាសអនុញ្ញាតផ្ទាល់(សុពលភាព២០ឆ្នាំ)<br>-ចំណាយក្នុងការបោះពុម្ពសំណុំលិខិតស្នើសុំ។<br><br>-ចំណាយលើការផ្សព្វផ្សាយសេចក្ដីព្រាងប្រកាសអនុញ្ញាតដល់មូលដ្ឋាន និងការដោះស្រាយវិវាទ ក្នុងករណីមានការតវ៉ា។<br><br>ឃ.ប្រកាសប្រកួតប្រជែង<br>-ចំណាយលើការសិក្សាសមិទ្ធិលទ្ធភាព និងការអង្កេតទីតាំងភូមិសាស្ត្រ។<br>-ចំណាយក្នុងការបោះពុម្ពសំណុំលិខិតស្នើសុំ។<br><br>-ចំណាយក្នុងការរៀបចំកិច្ចប្រជុំបឋមដើម្បីណែនាំអំពីការរៀបចំឯកសារចូលរួមដេញថ្លៃ។<br>-ចំណាយក្នុងការដេញថ្លៃ។<br><br>២.វិញ្ញាបនបត្រប្រតិបត្តិការ(សុពលភាព៥ឆ្នាំ)<br>ក.សម្រាប់វិញ្ញាបនបត្រប្រតិបត្តិការដំបូង៖<br><br>ចំណាយលើការចុះអធិការកិច្ច ដើម្បីពិនិត្យភាពត្រឹមត្រូវនៃការសាងសង់មធ្យោបាយផលិតកម្ម និងប្រព័ន្ធចែកចាយទឹកស្អាត ទៅតាមបទដ្ឋានគតិយុត្ត និងលក្ខណៈបច្ចេកទេស ដែលបានកំណត់ដោយក្រសួង ហើយទឹកស្អាតដែលនឹងចែកចាយមានគុណភាព និងសុវត្ថិភាពត្រឹមត្រូវតាមស្តង់ដាគុណភាពទឹកផឹកជាតិដល់មូលដ្ឋានដែលបានស្នើសុំធ្វើអាជីវកម្ម។ | គ.ប្រកាសអនុញ្ញាតផ្ទាល់(សុពលភាព២០ឆ្នាំ)<br>-ចំណាយសម្រាប់ប្រកាសអនុញ្ញាត។<br><br>-ចំណាយលើការរៀបចំឯកសារសមិទ្ធិលទ្ធភាព។<br>-ចំណាយលើការបញ្ជាក់ស្ថិតិប្រជាជនពីសាលាឃុំ។<br><br>ឃ.ប្រកាសប្រកួតប្រជែង<br>-ចំណាយសម្រាប់ប្រកាសអនុញ្ញាត។<br>-ចំណាយរៀបចំឯកសារដើម្បីចូលរួមដេញថ្លៃ។<br>-ចំណាយលើកិច្ចធានាក្នុងការចូលរួមដេញថ្លៃ៖<br>➢ មានទុនវិនិយោគយ៉ាងតិច ៣៥% នៃទុនវិនិយោគសរុប។<br>➢ តម្កល់ប្រាក់កក់ធានាចូលរួមដេញថ្លៃនៅធនាគារចំនួន៥០០០ ដុល្លាអាមេរិក។<br><br>២.វិញ្ញាបនបត្រប្រតិបត្តិការ(សុពលភាព៥ឆ្នាំ)<br>ក.សម្រាប់វិញ្ញាបនបត្រប្រតិបត្តិការដំបូង៖<br><br>ចំណាយសម្រាប់វិញ្ញាបនបត្រប្រតិបត្តិការដំបូង។ |

| | | |
|---|---|---|
| | **ខ.សម្រាប់វិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់៖**<br>ចំណាយលើការចុះអធិការកិច្ច ដើម្បីបញ្ជាក់ពីនិរន្តរភាពនៃមធ្យោបាយផលិតកម្ម និងប្រព័ន្ធចែកចាយទឹកស្អាត។<br>**៣.គុណភាពទឹក**<br>-ចំណាយលើការផ្សព្វផ្សាយដើម្បីបញ្ជ្រាបឱ្យមានការយល់ដឹង និងភ្ញាក់រលឹកយកសំណាកទឹកមកធ្វើការវិភាគឱ្យបានទៀងទាត់។<br>-ចំណាយចុះត្រួតពិនិត្យ និងវិភាគគុណភាពទឹក ក្នុងករណីចាំបាច់ដល់ទីតាំងអាជីវកម្ម តាមសភាពជាក់ស្តែង ។<br>-ចំណាយចុះពិនិត្យតាមដានដោយជូនដំណឹង ឬមិនមានការជូនដំណឹងជាមុន និងចុះពេលដែលមានបាតុភាពជាក់ស្តែង។<br>-ចំណាយលើសិក្ខាសាលា បណ្តុះបណ្តាលបច្ចេកទេសដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។<br>-ចំណាយលើការពង្រឹងយន្តការគ្រប់គ្រង និងតាមដានត្រួតពិនិត្យប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្មទឹក និងប្រព័ន្ធចែកចាយ។ | **ខ.សម្រាប់វិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់៖**<br>ចំណាយសម្រាប់វិញ្ញាបនបត្រប្រតិបត្តិការបន្ទាប់។<br><br>**៣.គុណភាពទឹក**<br>-ចំណាយក្នុងការវិភាគគុណភាពទឹក។<br>-ចំណាយលើយន្តការគ្រប់គ្រង និងតាមដានត្រួតពិនិត្យប្រភពទឹក ប្រព័ន្ធប្រព្រឹត្តកម្មទឹក និងប្រព័ន្ធចែកចាយ។ |
| ជម្រើសទី២៖ សំណើបញ្ញត្តិកម្ម | **I.ភាតព្វកិច្ច៖**<br>**១.ការផ្តល់អាជ្ញាបណ្ណ**<br>**ក.អាជ្ញាបណ្ណប្រកួតប្រជែង(ដេញថ្លៃ)៖**<br>-ក្រសួងរៀបចំនីតិវិធីដេញថ្លៃ។<br>-ក្រុមប្រឹក្សាឃុំ សង្កាត់ ផ្តល់ការឯកភាព ឬមិនឯកភាពលើនីតិវិធីដេញថ្លៃប្រកួតប្រជែង (បែបបទ និងនីតិវិធីសម្រាប់ដេញថ្លៃត្រូវកំណត់ដោយប្រកាសដោយឡែក)។<br>**ខ.អាជ្ញាបណ្ណផ្ទាល់(មិនប្រកួតប្រជែង)៖**<br>-អនុញ្ញាតឱ្យសិក្សាសមិទ្ធិលទ្ធភាពដល់អ្នកស្នើសុំ។<br>-លក់ពាក្យ និងទទួលពាក្យស្នើសុំអាជ្ញាបណ្ណ។ | **I.ភាតព្វកិច្ច៖**<br>**១.ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ**<br>**ក.អាជ្ញាបណ្ណប្រកួតប្រជែង(ដេញថ្លៃ)៖**<br><br>**ខ.អាជ្ញាបណ្ណផ្ទាល់(មិនប្រកួតប្រជែង)៖**<br>-ដាក់ពាក្យស្នើសុំសិក្សាសមិទ្ធិលទ្ធភាព។<br>-ដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកក្រសួងដោយមាន៖<br>➢ ការយល់ព្រមពីក្រុមប្រឹក្សាឃុំ សង្កាត់ |

| | | |
|---|---|---|
| | -ពិនិត្យពាក្យស្នើសុំក្នុងរយៈពេល៣០ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំពេញលេញ និងត្រឹមត្រូវ លើចំណុចដូចខាងក្រោម៖<br>➢ សមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេស<br>➢ ថ្លៃទឹក និងថ្លៃសេវាផ្សេងៗ<br>➢ កម្មវិធីសាងសង់មធ្យោបាយផ្គត់ផ្គង់ទឹកស្អាត<br>➢ គុណភាព និងបរិមាណប្រភពទឹក<br>➢ គុណភាពសេវា។<br><br>-ផ្សព្វផ្សាយសេចក្ដីព្រាងអាជ្ញាបណ្ណជាសាធារណៈ។<br>-ចេញអាជ្ញាបណ្ណ។<br><br>**២.វិញ្ញាបនបត្រប្រតិបត្តិការ**<br>-លក់ និងទទួលពាក្យស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការ។<br>-បន្ទាប់ពីចុះពិនិត្យមើលប្រព័ន្ធប្រព្រឹត្តិកម្ម និងមានការឯកភាព ក្រសួងត្រូវផ្តល់វិញ្ញាបនបត្រប្រតិបត្តិការ (បែបបទ និងនីតិវិធីសម្រាប់ស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការ ត្រូវកំណត់ដោយប្រកាសដោយឡែក)។<br><br>**៣.គុណភាពទឹក**<br>-ធ្វើការវិភាគគុណភាពទឹករៀងរាល់៣ខែម្តងស្របតាមស្តង់ដាជាតិ នៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។ | ➢ ការយល់ព្រមពីមន្ទីរឧស្សាហកម្ម និងសិប្បកម្មក្នុងដែនសមត្ថកិច្ចលើតំបន់សេវាដែលបានស្នើសុំ។<br><br>-ផ្តល់យោបល់លើសេចក្តីព្រាងអាជ្ញាបណ្ណក្នុងករណីពាក្យស្នើសុំមានចំណុចខ្វះខាត មុននឹងផ្សព្វផ្សាយជាសាធារណៈ ។<br><br>**២.វិញ្ញាបនបត្រប្រតិបត្តិការ**<br>ដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការ<br><br>**៣.គុណភាពទឹក**<br>-យកទឹកមកវិភាគគុណភាពទឹករៀងរាល់៣ខែម្តងស្របតាមស្តង់ដាជាតិ នៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។ |

| | | |
|---|---|---|
| | -ស្តង់ដាបច្ចេកទេសអប្បបរមាសម្រាប់សាងសង់មធ្យោបាយផ្គត់ផ្គង់ទឹកស្អាត ត្រូវកំណត់ដោយប្រកាសដោយឡែក។<br>-ពង្រឹងយន្តការគ្រប់គ្រង និងតាមដានត្រួតពិនិត្យការអនុវត្តរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។<br>-បណ្តុះបណ្តាលបច្ចេកទេសលើការផ្គត់ផ្គង់ទឹក។<br><br>៤.ថ្លៃទឹក<br>-ធ្វើការកំណត់ថ្លៃលក់ទឹកឱ្យបានសមស្រប ធៀបរវាងការចំណាយរបស់ប្រតិបត្តិករ និងលទ្ធភាពរបស់អ្នកប្រើប្រាស់ ព្រមទាំងផលប្រយោជន៍របស់រដ្ឋទាំងមូលផងដែរ។<br><br>II.**ការចំណាយ៖**<br>១.ការផ្តល់អាជ្ញាបណ្ណ<br>ក.អាជ្ញាបណ្ណប្រកួតប្រជែង(ដេញថ្លៃ)៖<br>រៀបចំនីតិវិធីដេញថ្លៃ<br>ខ.អាជ្ញាបណ្ណផ្ទាល់(មិនប្រកួតប្រជែង)៖<br>ចុះផ្សព្វផ្សាយសេចក្តីព្រាងអាជ្ញាបណ្ណជាសាធារណៈ | -ការផ្គត់ផ្គង់ទឹកស្អាត ត្រូវតែស្អាត និងមានសុវត្ថិភាព ដោយអនុលោមតាមច្បាប់។<br>-សម្របសម្រួល និងសហការ នៅពេលដែលមន្ត្រីមានសមត្ថកិច្ចចុះពិនិត្យតាមដាន និងចុះពេលដែលមានបាតុភាពជាក់ស្តែង។<br>-ទទួលការបណ្តុះបណ្តាលបច្ចេកទេសលើការផ្គត់ផ្គង់ទឹក។<br><br>៤.ថ្លៃទឹក<br>-ទទួលបាននូវតម្លៃទឹកសមស្របសម្រាប់ផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ ដែលមានការពេញចិត្តពីគ្រប់ភាគីពាក់ព័ន្ធ។<br><br>II.**ការចំណាយ៖**<br>១.ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ<br>ក.អាជ្ញាបណ្ណប្រកួតប្រជែង(ដេញថ្លៃ)៖<br><br>ខ.អាជ្ញាបណ្ណផ្ទាល់(មិនប្រកួតប្រជែង)៖<br>-ការដាក់ពាក្យស្នើសុំសិក្សាសមិទ្ធិលទ្ធភាព។<br>-ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមកក្រសួងដោយមានដោយមានការចំណាយផងដែរ៖<br>➢ ការយល់ព្រមពីក្រុមប្រឹក្សាឃុំ សង្កាត់<br>➢ ការយល់ព្រមពីមន្ទីរឧស្សាហកម្ម និងសិប្បកម្មក្នុងដែនសមត្ថកិច្ចលើតំបន់សេវាដែលបានស្នើសុំ។<br>-ផ្តល់យោបល់លើសេចក្តីព្រាងអាជ្ញាបណ្ណក្នុងករណីពាក្យស្នើសុំមានចំណុចខ្វះខាត មុននឹងផ្សព្វផ្សាយជាសាធារណៈ។ |

| | | |
|---|---|---|
| | **២.វិញ្ញាបនបត្រប្រតិបត្តិការ**<br>ចុះពិនិត្យមើលប្រព័ន្ធប្រព្រឹត្តិកម្ម និងមានការឯកភាព ក្រសួងត្រូវផ្តល់វិញ្ញាបនបត្រប្រតិបត្តិការ<br><br>**៣.គុណភាពទឹក**<br>-ធ្វើការវិភាគគុណភាពទឹករៀងរាល់៣ខែម្តងស្របតាមស្តង់ដាជាតិ នៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។<br>-ចុះពិនិត្យស្តង់ដាបច្ចេកទេសអប្បបរមាសម្រាប់សាងសង់មធ្យោបាយផ្គត់ផ្គង់ទឹកស្អាត។<br>-ពង្រឹងយន្តការគ្រប់គ្រង និងតាមដានត្រួតពិនិត្យការអនុវត្តរបស់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត។<br><br>-បណ្តុះបណ្តាលបច្ចេកទេសលើការផ្គត់ផ្គង់ទឹក។<br><br>**៤.ថ្លៃទឹក**<br>-ចំណាយទៅលើការលើកលែងពន្ធនាំចូលឧបករណ៍បច្ចេកទេស (ក្នុងករណីបានដាក់ពាក្យស្នើសុំធ្វើការវិនិយោទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)។<br>-លើកលែងពន្ធនាំចូលឧបករណ៍បច្ចេកទេស (ក្នុងករណីបានដាក់ពាក្យស្នើសុំធ្វើការវិនិយោទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា)។ | **២.វិញ្ញាបនបត្រប្រតិបត្តិការ**<br>ដាក់ពាក្យស្នើសុំវិញ្ញាបនបត្រប្រតិបត្តិការ<br><br>**៣.គុណភាពទឹក**<br>-យកទឹកមកវិភាគគុណភាពទឹករៀងរាល់៣ខែម្តងស្របតាមស្តង់ដាជាតិ នៅមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា។<br>-ការផ្គត់ផ្គង់ទឹកស្អាត ត្រូវតែស្អាត និងមានសុវត្ថិភាព ដោយអនុលោមតាមច្បាប់។<br>-សម្របសម្រួល និងសហការ នៅពេលដែលមន្ត្រីមានសមត្ថកិច្ចចុះពិនិត្យតាមដាន និងចុះពេលដែលមានបាតុភាពជាក់ស្តែង។<br>-ទទួលការបណ្តុះបណ្តាលបច្ចេកទេសលើការផ្គត់ផ្គង់ទឹក<br><br>**៤.ថ្លៃទឹក**<br>ទទួលបាននូវតម្លៃទឹកសមស្របសម្រាប់ផ្គត់ផ្គង់ដល់អ្នកប្រើប្រាស់ ដែលមានការពេញចិត្តពីគ្រប់ភាគីពាក់ព័ន្ធ។ |

## សម្រាប់អ្នកប្រើប្រាស់៖

- ទទួលបានទឹកស្អាតប្រើប្រាស់ភាគច្រើនមិនស្របតាមស្តង់ដារគុណភាពទឹកផឹកថ្នាក់ជាតិ
- ប៉ះពាល់ដល់សុខភាព និងមានការចំណាយសម្រាប់សុខភាព
- មិនមានទំនុបចិត្តលើសេវាករជាហេតុនាំឱ្យមិនបានប្រើប្រាស់ទឹកស្អាតដែលសេវាករបានផលិតបែរជាប្រើប្រាស់ទឹកអណ្តូងមានប្រភពមកពីកន្លែង ផ្សេងៗទៅវិញ
- មានបញ្ហាពីតម្លៃទឹកដោយទាមទារឱ្យចុះថ្លៃទឹក
- ប៉ះពាល់ដល់សុខភាពដោយទឹកមិនមានភាពអនុលោមតាមស្តង់ដា
- ប្រជាពលរដ្ឋនៅរអ៊ូរទាំនិងទាមទារឱ្យបញ្ចុះថ្លៃទឹកនៅតាមតំបន់ខ្លះ។

៤.២.ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម | **១.រដ្ឋាភិបាល៖**<br>-មិនចំណាយថវិកាសម្រាប់រៀបចំកសាងច្បាប់។<br>-ចំណេញពេលវេលា។<br>**២.ធុរជន៖**<br>-អនុវត្តតាមលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់។<br>-មិនចំណាយពេលវេលា និងធនធាន សម្រាប់ស្វែងយល់ និងអនុវត្តតាមច្បាប់។<br>**៣.អ្នកប្រើប្រាស់**<br>អ្នកប្រើប្រាស់ទឹកស្អាតមិនមានផលចំណេញទេ ទោះបីជាគាត់មានទឹកស្អាតប្រើប្រាស់ តែទឹកស្អាតនៅក្នុងតំបន់សេវាមួយចំនួន ជាពិសេសទឹកស្អាតឯកជន មិនមានភាពអនុលោមតាមស្តង់ដាគុណភាពទឹកស្អាតថ្នាក់ជាតិ ហើយថ្លៃទឹកនៅតែមានភាពចម្រូងចម្រាស់ ដោយអ្នកប្រើប្រាស់នៅតែទាមទារឱ្យចុះថ្លៃដដែល។ តំបន់មួយចំនួន នៅមិនទាន់មានសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅឡើយ។ |
| ជម្រើសទី២៖ ច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន | **១.រដ្ឋាភិបាល៖**<br>-ច្បាប់ជាលិខិតបទដ្ឋានគតិយុត្តដែលមានឋានានុក្រមខ្ពស់ថ្នាក់ជាតិ។<br>-មានភាពច្បាស់លាស់ប្រាកដនិយមលើនីតិវិធី និងបែបបទការងារ។<br>-បានកំណត់នូវតួនាទី និងការទទួលខុសត្រូវរបស់សមត្ថកិច្ចច្បាស់លាស់។<br>-មានទំនុបចិត្តពីធុរជន និងអ្នកប្រើប្រាស់ទឹកស្អាត។<br>-បង្កើនទំនុកចិត្ត និងទាក់ទាញការវិនិយោគលើវិស័យទឹកស្អាត។<br>-ផ្តល់នូវសិទ្ធិ និងកាតព្វកិច្ចដល់អ្នកវិនិយោគ និងអ្នកប្រើប្រាស់។<br>-មានការទុកចិត្តលើការវិនិយោគ និតជួយសម្របសម្រួលដល់អ្នកវិនិយោគអាចទទួលបាននូវឥណទានដែលមានការប្រាក់ទាប។<br>-ចូលរួមលើកកម្ពស់នីតិរដ្ឋក្នុងសង្គម។<br>-មានការពេញចិត្តពីអ្នកវិនិយោគ និងអ្នកប្រើប្រាស់លើបញ្ហាកំណត់ថ្លៃលក់ទឹក គុណភាពទឹក និរន្តរភាពទឹក។<br>-បានផ្តល់ទឹកស្អាតដែលមានគុណភាពស្របតាមស្តង់ដារគុណភាពទឹកស្អាតថ្នាក់ជាតិដល់អ្នកប្រើប្រាស់។ |

| | |
|---|---|
| | -ប្រជាពលរដ្ឋនៅតាមទីប្រជុំជនទូទាំងប្រទេសបានទទួលទឹកស្អាតប្រើប្រាស់គ្រប់ៗគ្នា។<br>-បង្កើនកម្រិតជីវភាពប្រជាពលរដ្ឋនៅតាមរយៈការផ្គត់ផ្គង់ទឹកស្អាត។<br>-លើកម្ពស់សុខមាលភាពប្រជាពលរដ្ឋ។<br>-ចូលរួមការពារបរិស្ថានសង្គម។<br>-ធានាអនុវត្តឱ្យសម្រេចបាននូវគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន និងកាត់បន្ថយភាពក្រីក្រ។<br>**២.ធុរជន៖**<br>-ទទួលបានទុនវិនិយោគមកវិញក្នុងអំឡុងពេលសមស្របណាមួយ។<br>-មានភាពប្រាកដនិយមនូវសិទ្ធិ និងកាតព្វកិច្ច។<br>-មានទំនុកចិត្តលើរាជរដ្ឋាភិបាលក៏ដូចជាស្ថាប័នមានសមត្ថកិច្ច។<br>-ទទួលបានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដល់ការប្រកបអាជីវកម្ម។<br>-មានទំនុកចិត្តលើគុណភាពទឹកស្អាត។<br>-រួមចំណែកក្នុងការលើកកម្ពស់កម្រិតជីវភាពប្រជាពលរដ្ឋ។<br>-រួមចំណែកការពារបរិស្ថានសង្គម។<br>-រួមចំណែកលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ ។<br>**៣.អ្នកប្រើប្រាស់៖**<br>-ទទួលបានទឹកស្អាតប្រើប្រាស់ប្រកបដោយគុណភាព តម្លាភាព និរន្តរភាព និងថ្លៃទឹកសមរម្យ<br>-នៅតាមទីប្រជុំជនមានទឹកស្អាតប្រើប្រាស់ដូចៗគ្នា<br>-មានសេដ្ឋកិច្ចល្អប្រសើរ។ |

## ៤.៣.វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/កស្តុតាង |
|---|---|---|---|
| ជម្រើសទី១៖ រក្សាស្ថានភាពដើម | -សហគ្រាសសាធារណៈ<br><br>-អង្គភាពរដ្ឋាករទឹក<br>-ក្រុមហ៊ុនទឹកស្អាតឯកជន | -ចំនួនពីរ គឺ ភ្នំពេញ និងសៀមរាប<br>-រដ្ឋាករទឹកចំនួន១១<br>-ឯកជនចំនួន២៣៧ | -អនុក្រឹត្យ<br><br>-ប្រកាស<br>-ប្រកាស |

| | |
|---|---|
| | -មិនមានលក្ខណៈប្រកដប្រជាក្នុងការកំណត់វិធាននៃការគ្រប់គ្រង ។<br>-កង្វះទំនុកចិត្តលើប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតពីសំណាក់អ្នកប្រើប្រាស់ទឹកស្អាត។<br>-លិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់មានឋានានុក្រមទាបពិបាកក្នុងការអនុវត្ត។<br>-កង្វះឥណទាន និងទំនុកចិត្តពីសំណាក់អ្នកផ្តល់ឥណទាន សម្រាប់អភិវឌ្ឍវិស័យទឹកស្អាត។ |
| ជម្រើសទី២៖<br>ច្បាប់ស្តីពី ការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន | -បង្កើតច្បាប់ដែលជាលិខិតបទដ្ឋានគតិយុត្តកម្រិតជាតិ ដែលមានភាពប្រាកដនិយម ធ្វើឱ្យមានការទុកចិត្តពីសំណាក់អ្នកវិនិយោគ ក៏ដូចជាអ្នកប្រើប្រាស់ទឹកស្អាត។<br>-យកចិត្តទុកដាក់ខ្ពស់លើបញ្ហាប្រភពទឹក ដូចជានិរន្តរភាព កិច្ចការពារបរិស្ថាន...។<br>-មានការទទួលខុសត្រូវខ្ពស់ទាំងសមត្ថកិច្ច ក៏ដូចជាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត<br>-បង្កើនកិច្ចសហការគ្នាល្អរវាងសមត្ថកិច្ចពាក់ព័ន្ធ ទាំងលើប្រភពទឹក ប្រព្រឹត្តិកម្មទឹក និងសេវាបណ្តាញ។<br>-មានប្រសិទ្ធភាព និងសមភាពក្នុងការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋប្រើប្រាស់ ទាំងផ្នែកសេវាកម្ម គុណភាព និរន្តរភាពទឹកស្អាត។ |

**៥.កិច្ចពិគ្រោះយោបល់បឋម**

កិច្ចពិគ្រោះយោបល់ត្រូវបានធ្វើឡើងតាមរបៀប៖

**១.កិច្ចប្រជុំ៖** ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តក្រសួងឧស្សាហកម្ម និងសិប្បកម្ម(MIH-RIA Team)ដោយមានកិច្ចសហការជាមួយអង្គការសហប្រតិបត្តិការជប៉ុន(JICA)បានរៀបចំកិច្ចប្រជុំនៅទីស្តីការក្រសួងចំនួន២៨លើក និងប្រជុំនៅមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ចំនួន ១៤ខេត្ត ៖ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគីរី ខេត្តស្វាយរៀង ខេត្តកំពត និងខេត្តព្រះសីហនុ។

**២.ការធ្វើអង្កេត៖** កម្រងសំណួរត្រូវបានរៀបចំឡើងដោយក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តក្រសួងឧស្សាហកម្ម និងសិប្បកម្ម(MIH-RIA Team) ដោយមានកិច្ចសហការជាមួយអង្គការសហប្រតិបត្តិការជប៉ុន(JICA)។

ការអង្កេតតាមរយៈកម្រងសំណួរ ត្រូវបានធ្វើឡើងដោយមន្ត្រី MIH-RIA Team និងបុគ្គលិកអង្គការសហប្រតិបត្តិការជប៉ុន(JICA) នៅខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តប៉ៃលិន ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី ខេត្តមណ្ឌលគីរី ខេត្តស្វាយរៀង ខេត្តកំពត និងខេត្តព្រះសីហនុ។

អ្នកឆ្លើយសំណួរត្រូវបានជ្រើសរើសក្នុងចំណោមអ្នកដែលមានការពាក់ព័ន្ធនឹងទឹកស្អាត(ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអ្នកប្រើប្រាស់ទឹកស្អាត) ដែលក្នុងនោះប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតមានចំនួន៦៧នាក់ និងអ្នកប្រើប្រាស់ទឹកស្អាតមានចំនួន៤៥៧នាក់ ក្នុងខេត្តចំនួន១៤។

**លទ្ធផល**នៃកិច្ចពិគ្រោះយោបល់ដែលធ្វើឡើងតាមរយៈកិច្ចប្រជុំ និងពិគ្រោះយោបល់ បានបង្ហាញថាប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួន៦២នាក់បានឆ្លើយគាំទ្រ និងចំនួន៥នាក់មិនឆ្លើយនឹងសំនួរ ក្នុងចំណោមប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតចំនួនសរុប

៦៧នាក់ ហើយអ្នកប្រើប្រាស់ទឹកស្អាតចំនួនសរុប៤៥៧នាក់ដែលបានជួបពិគ្រោះយោបល់បានគាំទ្រ លើសំណើសេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន(ជម្រើសទី២)។ នៅក្នុងនោះផងដែរក៏មានការលើកឡើងនូវសំណូមពរមួយចំនួនពីសំណាក់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត និងអ្នកប្រើប្រាស់ទឹកស្អាត ដូចជា៖

**១.ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត៖**

-ស្នើសុំឱ្យច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន ហើយអនុវត្តប្រកបដោយតម្លាភាព និងបំរើផលប្រយោជន៍ប្រទេសជាតិពិតប្រាកដ។

-ស្នើសុំឱ្យមានកិច្ចសហការល្អរវាងរដ្ឋ និងឯកជន ក្នុងការដាក់លូ និងធ្វើផ្លូវ។

-ស្នើសុំក្រសួង ឬមន្ទីរ ជួយអន្តរាគមន៍ឱ្យទាន់ពេលវេលាពេលនៅដែលប្រតិបត្តិករជួបបញ្ហា។

-ស្នើសុំឱ្យក្រសួង ឬមន្ទីរធ្វើការផ្សព្វផ្សាយអំពីអត្ថប្រយោជន៍នៃការប្រើប្រាស់ទឹកស្អាត។

-ជួយឱ្យរួចពន្ធលើសេវាពាក់ព័ន្ធនឹងទឹកស្អាត ដើម្បីឱ្យប្រជាពលរដ្ឋបានទទួលទឹកស្អាតប្រើប្រាស់ក្នុងតម្លៃថោក។

-ស្នើសុំផ្តល់ប្រកាសអនុញ្ញាតធ្វើអាជីវកម្មឱ្យបានឆាប់រហ័ស និង បង្កភាពងាយស្រួលលើឯកសារក្នុងការស្នើសុំប្រកាសអនុញ្ញាតដែលមានសុពលភាព២០ឆ្នាំ។

-ស្នើសុំកុំឱ្យសេវាកម្មផ្គត់ផ្គង់ទឹកស្អាតត្រួតស៊ីគ្នា(បណ្តាញជាន់គ្នា...)។

-ជួយទប់ស្កាត់ចំពោះការរកស៊ីដែលមិនមានច្បាប់អនុញ្ញាតត្រឹមត្រូវ។

-សម្រួលរាល់កង្វះខាតលើការពង្រីកបណ្តាញ បច្ចេកទេស និងការឧបត្ថម្ភធន។

-ស្នើសុំឱ្យជួយស្វែងរកប្រភពទឹក។

-ស្នើសុំឱ្យជួយបច្ចេកទេសលើប្រព័ន្ធផលិតកម្ម។

-ស្នើសុំកុំឱ្យមានការបញ្ចុះតម្លៃទឹកស្អាត។

-ជួយស្វែងរកឥណទានដែលមានអត្រាការប្រាក់ទាបសម្រាប់ជួយដល់ប្រតិបត្តិករផ្គត់ផ្គត់ទឹកស្អាត។

-ស្នើសុំជួយការពារ និងបង្កភាពងាយស្រួលដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតដែលមានច្បាប់អនុញ្ញាតត្រឹមត្រូវ។

**២.អ្នកប្រើប្រាស់ទឹកស្អាត៖**

-ស្នើសុំបញ្ចុះតម្លៃថ្លៃលក់ទឹកស្អាត។

-ស្នើសុំបញ្ចុះតម្លៃភ្ជាប់បណ្តាញទឹកស្អាត។

-ស្នើសុំឱ្យទឹកផលិតប្រកបដោគុណភាព។

-ស្នើសុំឱ្យការផ្គត់ផ្គង់ទឹកស្អាត២៤ម៉ោង/២៤ម៉ោង។

-ស្នើសុំឱ្យនាឡិការស្ទង់មានភាពត្រឹមត្រូវ។

១. ទិន្នន័យខេត្តដែលបានចុះពិគ្រោះយោបល់




២.ចំនួនអ្នកផ្គត់ផ្គង់ទឹកស្អាត និងអ្នកប្រើប្រាស់ទឹកស្អាត ដែលបានធ្វើការពិគ្រោះយោបល់ជាមួយ



### ៣.លទ្ធផលដែលបានពិគ្រោះយោបល់លើការគាំទ្រឱ្យមានសំណើរសេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន

#### ៣.១.ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាត៖




#### ៣.២.អ្នកប្រើប្រាស់ទឹកស្អាត



៤.មូលហេតុដែលអ្នកផ្គត់ផ្គង់ទឹកស្អាតគាំទ្រនូវសំណើសេចក្តីព្រាងច្បាប់ ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន




## ៦.សន្និដ្ឋាន

តើចាំបាច់ធ្វើ RIS ដែរឬទេ ?

☐ **ចាំបាច់**

☑ **មិនចាំបាច់**

ជាយោបល់មិនចាំបាច់ធ្វើការវាយតម្លៃផលប៉ះពាល់ពេញលេញ (RIS)លើសេចក្តីព្រាងច្បាប់នេះទេ ព្រោះការវាយតម្លៃផលប៉ះពាល់បឋម (PAS)មានលក្ខណៈគ្រប់គ្រាន់ និងអាចទទួលយកបាន ដោយច្បាប់ចែងនូវចំណុចគោលៗនៃវិធាននីមួយៗទុកសម្រាប់ឱ្យរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងទទួលបន្ទុកយកមករៀបចំជាគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ ដោយមានភាពអនុលោម។

**ដូចនេះ ជម្រើសទី២ សេចក្តីព្រាងច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន ត្រូវបានជ្រើសរើស។**

## ៧. ការអនុវត្តនិងការតាមដានត្រួតពិនិត្យ ប្រសិនបើបញ្ញត្តិកម្មត្រូវបានជ្រើសរើស៖

ក្រោយពេលច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន ត្រូវបានរដ្ឋសភាបានអនុម័ត និងព្រះមហាក្សត្រទ្បាយព្រះហសត្ថលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើជាផ្លូវការរួចមក វិធានការអនុវត្ត និងតាមដាន មានដូចខាងក្រោម៖

-ក្រសួងត្រូវធ្វើការផ្សព្វផ្សាយអំពីខ្លឹមសារច្បាប់នេះ ឱ្យបានទូលំទូលាយដើម្បី បញ្ជ្រាបការយល់ដឹងដល់អ្នកផ្គត់ផ្គង់សេវាផ្គត់ផ្គង់ទឹកស្អាត និងអ្នកពាក់ព័ន្ធ ព្រមទាំងដាក់កំរិតឱ្យមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី-ខេត្ត ចុះផ្សព្វផ្សាយបន្តដល់មូលដ្ឋាន ដើម្បីធានាដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។

-ក្រសួងត្រូវរៀបចំគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងលិខិតបទដ្ឋានគតិយុត្តនានាឱ្យស្របតាមច្បាប់ស្តីពីការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជន និងធ្វើការផ្សព្វផ្សាយ ដើម្បីគ្រប់គ្រងសេវាផ្គត់ផ្គង់ទឹកស្អាតប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។

-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ជាពិសេសអគ្គនាយកដ្ឋានទទួលបន្ទុក និងអង្គភាពពាក់ព័ន្ធ គួរធ្វើការត្រួតពិនិត្យតាមដាន វាយតម្លៃលើប្រសិទ្ធភាពនៃការអនុវត្តច្បាប់នេះ ធ្វើការបណ្តុះបណ្តាលអំពីបច្ចេកទេស ការផ្តល់បច្ចេកវិទ្យា និងស្វែងរកដៃគូរអភិវឌ្ឍន៍ ព្រមទាំងសម្របសម្រួលជាមួយធនាគារជាតិ និងគ្រឹះស្ថានហិរញ្ញវត្ថុនានាក្នុងការផ្តល់ឥណទាន ដែលមានអត្រាការប្រាក់ទាបឬស្មើសូន្យ ព្រមទាំងការបន្ធូបន្ថយពន្ធឬលើកលែងពន្ធ ដើម្បីផ្តល់លទ្ធភាពដល់ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតក្នុងការរៀបចំប្រព័ន្ធប្រព្រឹត្តិកម្មនិងប្រព័ន្ធចែកចាយតាមលក្ខណៈបច្ចេកទេស ធ្វើការពង្រីកតំបន់សេវាកម្ម និងការវិនិយោគនៅតាមតំបន់ដាច់ស្រយាល។

-អគ្គនាយកដ្ឋានទឹកស្អាត ត្រូវរៀបចំបែបបទនីតិវិធីឱ្យបានត្រឹមត្រូវ ដើម្បីវាយតម្លៃ និងកំណត់ថ្លៃទឹកឱ្យបានសមស្រប ដែលអាចទទួលយកបានទាំងប្រតិបត្តិករ ក៏ដូចជាអ្នកប្រើប្រាស់ទឹកស្អាត។

-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវការពារទប់ស្កាត់ផលប៉ះពាល់លើបណ្តាញ ដែលបណ្តាលមកពីការរៀបចំហេដ្ឋារចនាសម្ព័ន្ធតាមរាជធានី-ខេត្ត តាមរយៈកិច្ចសហការល្អជាមួយគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ។

-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវធានានិរន្តរភាពនៃប្រភពទឹក កិច្ចការពារការបំពុលប្រភពទឹក សម្រាប់យកមកធ្វើប្រព្រឹត្តិកម្មទឹកស្អាត។

ក្រុមការងារវាយតម្លៃផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវពិនិត្យ និងវាយតម្លៃលើផលប៉ះពាល់ជាក់ស្តែងនៃការអនុវត្ត និងលើកយោបល់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេចនូវភាពខ្វះចន្លោះនៃច្បាប់ធៀបទៅនឹងបច្ចុប្បន្នភាពនៃតម្រូវការរៀងរាល់៥ឆ្នាំម្តង។

| ដំណើរការ | ឈ្មោះ | មុខងារ |
|---|---|---|
| **រៀបចំដោយ ក្រុមការងារវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តក្រសួងឧស្សាហកម្ម និងសិប្បកម្ម** | លោក ចាតសូ សុភ័ក្រ | អគ្គនាយករង និងជាប្រធានក្រុមការងារRIA |
| | លោក ចេង លឹមដី | ប្រធាននាយកដ្ឋាន និងជាអនុប្រធានក្រុមការងារRIA |
| | លោក សោម គន្ធា | ប្រធាននាយកដ្ឋាន និងជាសមាជិកក្រុមការងារRIA |
| | លោក ហេង ប៊ុនហួរ | អនុ.នាយកដ្ឋាន និងជាសមាជិកក្រុមការងារRIA |
| | លោកស្រី សេង ស៊ីណា | ប្រធានការិយាល័យ និងជាប្រធានលេខាធិការRIA |
| | លោក ថាច់ កេត | អនុ.ការិយាល័យ និងជាសមាជិកលេខាធិការRIA |

| | | |
|---|---|---|
| | កញ្ញា តាន់ ឆេងប៉ | មន្ត្រីនៃនាយកដ្ឋាននីតិកម្ម |
| | លោក ប៊ុន ចាន់គង់ | អនុប្រធាននាយកដ្ឋាន |
| | លោក ហ៊ិន វុទ្ធី | អនុប្រធានការិយាល័យ នៃ អគ្គនាយកដ្ឋានទឹកស្អាត |
| | កញ្ញា ថាន់ ស្រីធួក | អនុប្រធានការិយាល័យ នៃ អគ្គនាយកដ្ឋានទឹកស្អាត |
| **សហការរៀបចំដោយ ទីភ្នាក់ងារសហប្រតិបត្តិការជប៉ុន ទទួលបន្ទុកទឹកស្អាតប្រចាំ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម** | Mr NONAKA Hiroyuki | JICA Expert |
| | Mr HIROWATARI Hiroshi | JICA Expert |
| | កញ្ញា វ៉ាន់ ច័ន្ទកញ្ញា | JICA Staff |
| | កញ្ញា លីវ លីនី | JICA Staff |
| | លោក សំរឹទ្ធ សុភាព | Technical Staff |